# សង្ខេបប្រតិបត្តិ

បច្ចុប្បន្ននេះ ផែនការកំពុងត្រូវបានធ្វើដើម្បីសាងសង់ទំនប់វារីអគ្គិសនីមួយកម្ពស់ ៣០-៣២ ម៉ែត្រ ដែលមានសមត្ថភាពផលិតអគ្គិសនីពី ២៤០ មេហ្គាវ៉ាត់ដល់ ៣៦០ មេហ្គាវ៉ាត់ នៅលើព្រែកហ៊ូសាហុងនៃទន្លេមេគង្គ។ គម្រោងនេះនឹងមានទីតាំងនៅខាងក្រោមមួយគីឡូម៉ែត្រប៉ែកខាងជើងនៃព្រំដែនឡាវ-កម្ពុជា នៅក្នុងតំបន់ល្បាក់ខោននៃស្រុកខុង ខេត្តចំប៉ាសាក់ ភាគខាងត្បូងប្រទេសឡាវ។ គេឃើញមានការបារម្ភផ្សេងៗទាក់ទិននឹងទំនប់ដនសាហុង (DSD) ប៉ុន្តែ ការបារម្ភចម្បងគេទាក់ទិននឹងផលប៉ះពាល់ដែលអាចមានលើធនធានជលផល និងជាពិសេស ជីវចម្រុះជលជាតិនិងជលផលធម្មជាតិ។ ផលប៉ះពាល់លើការបំលាស់ទីរបស់មច្ឆាជាតិគឺស្ថិតនៅក្នុងចំណោមផលប៉ះពាល់សំខាន់បំផុត។ ឯកសារនេះផ្តោតលើផលប៉ះពាល់ដែលអាចមានរបស់ទំនប់ដនសាហុង លើមច្ឆាជាតិនិងជលផល និង ជាពិសេសផលប៉ះពាល់តំបន់នៃគម្រោងទាក់ទិននឹងជលផល រួមទាំងផលប៉ះពាល់ដែលអាចមានរបស់វាលើសន្តិសុខស្បៀង អាហារូបត្ថម្ភ និង ការកាត់បន្ថយភាពក្រីក្រនៅប្រទេសឡាវ និង ប្រទេសនានានៅក្នុងតំបន់មេគង្គ។

របកគំហើញនានានៃការសិក្សានេះ - រួមទាំងការចុះដល់មូលដ្ឋានដែលបានធ្វើអស់ពេលច្រើនឆ្នាំ និង ជាពិសេស ក្នុងការរៀបចំដើម្បីសរសេររបាយការណ៍នេះ - បង្ហាញថាពូជត្រីផ្សេងៗដែលទ្រទ្រង់ជលផលសំខាន់ៗនៅក្នុងទូទាំងតំបន់ធ្វើបំលាស់ទីផ្លូវឆ្ងាយឡើងចុះទន្លេមេគ្គងឆ្លងកាត់ល្បាក់ខោនតាមរដូវផ្សេងៗនៃឆ្នាំ។ គេឃើញច្បាស់ថា សម្រាប់ប្រជាជនជាច្រើននៅខាងលើជាប់ល្បាក់ខោន ត្រីភាគច្រើនដែលគេចាប់បានគឺធ្វើបំលាស់ទីច្រើន និង មានប្រភពចេញពីខាងក្រោមល្បាក់ខោន។ នៅខាងលើឆ្ងាយពីទន្លេមេគង្គ ប្រភេទត្រីភាគច្រើនដែលធ្វើដំណើរឆ្លងកាត់ល្បាក់ខោន នៅតែជាផ្នែកដ៏ធំមួយនៃជលផល ជាពិសេស នៅតាមរដូវខ្លះនៃឆ្នាំ។ នៅខេត្តចំប៉ាសាក់ បទសម្ភាសន៏បង្ហាញថាពូជត្រីសំខាន់ៗទាំងអស់ដែលគេឃើញមាននៅក្នុងការបំលាស់ទីឆ្លងកាត់ល្បាក់ខោន នៅតែមានច្រើននៅឡើយចំពោះត្រីដែលរកបាននៅក្នុងមូលដ្ឋាន។ នៅខាងលើទន្លេឆ្ងាយពីនេះទៀតនៅក្នុងខេត្តសាវណ្ណាខេត្ត ខាមួន បូលិខាំសៃ និង ក្រុងវៀងច័ន្ទ មច្ឆាជាតិធ្វើបំលាស់ទីទាំងនេះនៅតែបន្តគឺជាចំណែកដ៏សំខាន់មួយសម្រាប់ជលផលរួមរបស់ប្រជាជន។ ត្រីជាច្រើនដែលធ្វើបំលាស់ទីឡើងលើល្បាក់ខោន ក៏ប្រហែលជាចូលទៅក្នុងដៃទន្លេមេគង្គធំៗជាង ដូចជា ទន្លេមូននៅប្រទេសថៃ និង ទន្លេសេដន និង សេបាងឆៀង នៅប្រទេសឡាវ។

ព្រែកហ៊ូសាហុងត្រូវបានគេមើលឃើញថាគឺជាព្រែកតែមួយគត់ដែលមច្ឆាជាតិអាចឆ្លងកាត់ដោយងាយ

ស្រួលពេញ១មួយឆ្នាំ ហើយព្រែកនេះមានសារៈសំខាន់ជាពិសេសសម្រាប់ការធ្វើបំលាស់ទីផ្លូវឆ្ងាយនារដូវប្រាំង ទៅខាងលើទន្លេ។ ដោយសារមច្ឆាជាតិទាំងនេះភាគច្រើនឆ្លងកាត់តាមព្រែកហ៊ូសាហុង - ដែលមុខជាត្រូវបាន បិទដោយទំនប់ដនសាហុង - គេឃើញមានហានិភ័យខ្ពស់ដែលទំនប់នេះអាចបណ្តាលឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរ ដល់ជលផលនៅឆ្ងាយខាងលើខ្សែទឹកទាំងនៅភាគខាងជើងប្រទេសឡាវ និង ភាគខាងជើងប្រទេសថៃ។ ម្យ៉ាង ទៀត មច្ឆាជាតិមុខជាមិនអាចបញ្ចប់វដ្តជីវិតវានៅខាងលើខ្សែទឹកពីល្បាក់ខោនបានទេ ដូច្នេះ មច្ឆាជាតិនៅខាង ក្រោមខ្សែទឹកពីទំនប់នេះ ក៏មុខជានឹងរងការគម្រាមកំហែងធ្ងន់ធ្ងរផងដែរ រួមទាំងជលផលដ៏សំខាន់នៅក្នុងបឹង ទន្លេសាបនៅប្រទេស និង ដីសណ្តរមេគង្គនៅប្រទេសវៀតណាម។ បឹងទន្លេសាប ទ្រទ្រង់ជលផលដ៏សំខាន់បំផុត នៅកម្ពុជា ខណៈដែលដីសណ្តរមេគង្គនៅវៀតណាមក៏ទ្រទ្រង់ជលផលច្រើនផងដែរ។

ហេតុដូច្នេះ ជលផលនិងជីវភាពពាក់ព័ន្ធ ទាំងនៅខាងលើឆ្ងាយនិងនៅខាងក្រោមឆ្ងាយពីទំនប់ មុខជា រងការខូចខាតធ្ងន់ធ្ងរដោយទំនប់ដនសាហុង។ លើសពីនេះទៀត ពូជមច្ឆាជាតិដែលអាចត្រូវបាត់បង់នៅខាងលើ ខ្សែទឹកនៃល្បាក់ខោន រួមមាន ប្រភេទត្រីផ្សេងៗច្រើនដែលមានសារៈសំខាន់មិនត្រឹមតែសម្រាប់ជីវភាពក្នុង មូលដ្ឋានប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងមានសារៈសំខាន់ផងដែរសម្រាប់ប្រព័ន្ធអេកូឡូស៊ីរួមនៃអាងទន្លេមេគង្គ។ ពូជត្រីទាំងនេះ រួមមានត្រីរៀល (*ប៉ាសយ* ជាភាសាឡាវ) ដែលគឺជាប្រភពដ៏សំខាន់មួយនៃអាហារសម្រាប់ ប្រភេទត្រីស៊ីត្រីច្រើនប្រភេទ ក៏ដូចជា ត្រីផ្សោតនៅក្នុងទន្លេមេគង្គផងដែរ។

វិធានការសម្រាលផលប៉ះពាល់ ត្រូវបានគេស្នើឡើងនៅក្នុងសេចក្តីព្រាងវាយតម្លៃផលប៉ះពាល់បរិស្ថាន នៃទំនប់ដនសាហុង ប៉ុន្តែ ផ្អែកលើចំណេះដឹងបច្ចុប្បន្ននិងបទពិសោធន៍កន្លងមក វិធានការទាំងនេះទំនងជានឹងមិន មានប្រសិទ្ធិភាពពេញលេញទេ ហើយហានិភ័យនៃផលប៉ះពាល់ធ្ងន់ធ្ងរគឺខ្ពស់។ ស្ពានដែសម្រាប់ច្រកមច្ឆាជាតិ ឆ្លងកាត់នៅក្នុងតំបន់មេគង្គនិងនៅក្នុងពិភពលោក គឺអន់ខ្សោយណាស់ ហើយវាគឺជាការលំបាកខ្លាំងក្នុងការ អភិវឌ្ឍច្រកត្រីឆ្លងកាត់ដែលអាចសម្រួលឱ្យត្រីគ្រប់ប្រភេទទាំងអស់ឆ្លងកាត់នៅក្នុងគ្រប់រដូវ។ ម្យ៉ាងទៀត គេមុខជាមិនអាចធ្វើដូចស្ថានភាពនៃព្រែកហ៊ូសាហុងនៅក្នុងព្រែកជាប់នោះមួយឡើយ ដោយសារជម្រើសព្រែក ដែលមានទាំងអស់សម្រាប់ការឆ្លងកាត់មច្ឆាជាតិ គឺសុទ្ធតែមានសភាពចង្អៀតជាងច្រើន ជាមួយបរិមាណទឹកតិច ជាងច្រើន។

ជាចុងក្រោយ ការបាត់បង់ជលផលនៅក្នុងតំបន់មេគង្គពីទំនប់ដនសាហុង អាចប៉ះពាល់ជាអវិជ្ជមានដល់ ស្ថានភាពអាហារូបត្ថម្ភរបស់ប្រជាជនរាប់សែននាក់ ឬ រហូតដល់ទៅរាប់លាននាក់ ដែលពឹងអាស្រ័យលើជលផល ទាំងនេះ ដែលជាហេតុកាត់បន្ថយសុខភាពរបស់ប្រជាជនមួយក្រុមធំ ជាពិសេស នៅតាមតំបន់មួយចំនួននៃ

ប្រទេសឡាវ កម្ពុជា និង ថៃ ដែលនៅទីនោះ ស្តង់ដារអាហារូបត្ថម្ភមានលក្ខណៈទាបរួចទៅហើយ។ ជលផលទន្លេមេគង្គដែលរងការគម្រាមកំហែង គឺសំខាន់ក្រៃលែងសម្រាប់បំពេញសេចក្តីត្រូវការអាហារូបត្ថម្ភរបស់ប្រជាជនក្នុងតំបន់។ ប្រជាជនទាំងឡាយដែលរស់នៅជិតទំនប់ ទាំងនៅខាងលើនិងនៅខាងក្រោមទន្លេពីគម្រោង ជាទូទៅ មុខជារងផលប៉ះពាល់ច្រើនជាងអ្នកដែលនៅឆ្ងាយ។ ប៉ុន្តែ ផលប៉ះពាល់មុខជាបន្តទៅដល់រាប់ពាន់គីឡូម៉ែត្រ ចាប់តាំងពីដែនដីសណ្តរមេគង្គនៅប្រទេសវៀតណាម ឆ្លងកាត់ប្រទេសកម្ពុជា ឡាវ និង ថៃ ដោយបន្តទៅដល់ភាគខាងជើងប្រទេសឡាវ។

ចំពោះមុខផលប៉ះពាល់ទូលាយនិងស៊ីជម្រៅនៃទំនប់ដនសាហុង គម្រោងនេះអាចធ្វើឱ្យរដ្ឋាភិបាលទាំងឡាយនៅក្នុងតំបន់ ជាពិសេសរដ្ឋាភិបាលនៃប្រទេសឡាវនិងកម្ពុជា ជួបការលំបាកកាន់តែច្រើនឡើងក្នុងការឈានដល់គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទាក់ទិននឹងសុខភាពរបស់ខ្លួន ឬមួយគោលដៅរបស់ខ្លួនសម្រាប់ការកាត់បន្ថយភាពក្រីក្រ។ សម្រាប់រដ្ឋាភិបាលជាតិនិងទីភ្នាក់ងារផ្តល់ជំនួយអន្តរជាតិទាំងឡាយដែលគាំទ្ររដ្ឋាភិបាលជាតិទាំងនេះ ទំនប់ដនសាហុងគប្បីគឺជាការបារម្ភចម្បងមួយ។